នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Dec-2013, 08:11
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (ជាមួយឧបសម្ព័ន្ធសម្ងាត់ ក)

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ផែនការសវនាការសម្រាប់សំណុំរឿង ០០២/០២**
**ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា (ជាមួយ ឧបសម្ព័ន្ធសម្ងាត់ ក)**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Arthur VERCKEN
Anta GUISSE

## សេចក្តីសន្និដ្ឋាន

១. ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំរៀបចំសវនាការដែលនឹងចូលមកដល់ចាប់ពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ នេះ និងបន្ថែមទៅលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ ដែលបានដាក់ជូនកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាសូមដាក់ជូន **ឧបសម្ព័ន្ធសម្ងាត់** ក ដែលជាផែនការមួយសម្រាប់សវនាការលើទីតាំងឧក្រិដ្ឋកម្មនានាដែលបានស្នើឡើងដើម្បីដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២ រួមមានបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបឋម ឬជាបណ្តោះអាសន្នដែលសហព្រះរាជអាជ្ញាមានបំណងស្នើឡើងសម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗ និងវគ្គសវនាការនីមួយៗ។ **ឧបសម្ព័ន្ធ** ក ត្រូវបានដាក់នៅពេលនេះ ដើម្បីជួយដល់អង្គជំនុំជម្រះដើម្បីឲ្យធ្វើការវាយតម្លៃអំពីរយៈពេលដែលត្រូវការចាំបាច់សំរាប់ការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០២ បើសិនជាទីតាំងឧក្រិដ្ឋកម្មនិងព្រឹត្តិការណ៍ទាំងឡាយដែលបានស្នើដោយសហព្រះរាជអាជ្ញាត្រូវបានដាក់បញ្ចូល ហើយនិងដើម្បីផ្តល់ជូនដល់អង្គជំនុំជម្រះ និងភាគីនានានូវសញ្ញាបង្ហាញជាបឋមអំពីសាក្សីទាំងឡាយដែលសហព្រះរាជអាជ្ញាអាចនឹងស្នើសុំសំរាប់ការជំនុំជម្រះក្តីខាងលើនេះ ។ សហព្រះរាជអាជ្ញា សូមកត់សំគាល់ថា ការពិនិត្យឡើងវិញ និងវាយតម្លៃរបស់ខ្លួនលើសក្ខីកម្មរបស់សាក្សីដែលចាំបាច់កំពុងតែបាននិងបន្តធ្វើ ហើយបញ្ជីឈ្មោះសាក្សីស្ថាពរមួយនឹងត្រូវបានដាក់ជូន បន្ទាប់ពីវិសាលភាពនៃសំណុំរឿងលេខ០០២/០២ ត្រូវបានសំរេចនិងកាលបរិច្ឆេទត្រូវបានកំណត់ដោយអង្គជំនុំជម្រះសំរាប់ឲ្យគ្រប់ភាគីទាំងអស់ដាក់នូវបញ្ជីសាក្សី និងឯកសារផ្សេងៗ ។

២. ជាបន្ថែមពីលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលទាក់ទងនឹងទីកន្លែងឧក្រិដ្ឋកម្ម សម្រាប់សំណុំរឿង០០២/០២ដែលបានស្នើសុំ នៅក្នុង**ឧបសម្ព័ន្ធ** ក មានរួមបញ្ចូលនូវសាក្សី និងអ្នកជំនាញទាំងឡាយដែលទាក់ទងនឹង៖ តួនាទីរបស់ជនជាប់ចោទ អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម និង គោលនយោបាយជាក់លាក់នានារបស់ បកក ដែលនៅមិនទាន់ត្រូវបានធ្វើការស្តាប់ចម្លើយនៅក្នុងពេលសវនាការលើសំណុំរឿង ០០២/០១ នៅឡើយ។ ការស្នើសុំឲ្យមានការបែងចែកពេលវេលាសម្រាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញ ម្នាក់ៗគឺមានដាក់ជាអក្សរដិតក្រាស់នៅពីខាងមុខកៀកជាប់នឹងឈ្មោះរបស់បុគ្គលនីមួយៗ។ ដើម្បីស្តាប់ចម្លើយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលសហព្រះរាជអាជ្ញាបានដាក់ស្នើនៅក្នុង **ឧបសម្ព័ន្ធសម្ងាត់** ក ខាងលើនេះគឺចាំបាច់តម្រូវឲ្យធ្វើសវនាការជាសរុបចំនួន ៩៦ថ្ងៃ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |